# កាសិកោវាទ

បោះពុម្ពលើកទីមួយ

---

ការផ្សាយរបស់

បណ្ណាគារនាគពន្ធ

តាំងនៅជិតបន្ទីរក្រសួងព្រះនគរបាលសៀមរាប - អង្គរ

ព.ស. ២៤៩៦ គ.ស. ១៩៥២

---

Librairie NEAK-PEAN
*près du Commissariat de Police*
*Urbaine* à Siemréap.

CA53

លោកឧកញ៉ា ប្រសើរបញ្ញង់

ម៉ុក-ទូន អ្នកស្រី អឿន នៅសៀមរាប

មានសទ្ធាជ្រះថ្លា ចែក សៀវភៅភាសិតតាទាវ

ចំនួន ២០០ សៀវភៅផ្សាយជាធម្មទាន ក្នុង

ឱកាសបុណ្យ ព.ស ២.៥០០ ទិស្នា ។

សូមឧទ្ទិសឧត្តមផលនេះ ជូនដល់លោក-អ្នកមាន

គុណទាំងឡាយ មានមាតាបិតាជាដើម ។

tous droits réservés

# ភាសិតោវាទ

សុភាសិត

ប្រដៅឲ្យស្រឡាញ់ប្រទេស ជាតិ-សាសនា

មហាក្សត្រ

---

ការផ្សាយរបស់ បណ្ណាគារនាគពន្ធ

សៀមរាប - អង្គរ

(រក្សាសិទ្ធិ)

ព.ស. ២៤៩៦ - គ.ស. ១៩៥២

# អារម្ភកថា

ភាសាសុភាសិត ជាភាសារមែងចាប់ចិត្តរបស់អ្នកប្រាជ្ញ ហេតុនេះបានជាសុភាសិតទាំងឡាយមិនសាបសូន្យទៅណា មានមនុស្សនិយមរាប់អានចាំទុកប្រដៅគ្នាតរៀងមក ។

ខ្ញុំមានសេចក្ដីពេញចិត្តនឹងភាសាសុភាសិតពន់ពេក ទើបបានខ្ញុំដកស្រង់ពីសៀវភៅសរសេរនៃពាក្យសុភាសិតរបស់អ្នកឧកញ៉ាសុតន្តប្រីជាឥន្ទ ខ្លះនឹងស្រង់ពីទីដទៃខ្លះ មករៀបរៀងតាមពាក្យ ៧ និង ៨ ឲ្យងាយស្រួលដល់អ្នកអានទាំងឡាយ, ដើម្បីបោះពុម្ពផ្សាយទុកក្នុងកម្ពុជរដ្ឋជាប្រយោជន៍ទូទៅ, ឲ្យឈ្មោះថា៖ « ភាសិតោវាទ » ។

លុះខ្ញុំបានដកស្រង់រៀបរៀងរួចស្រេចហើយ ទើបបានយកទៅប្រគេនព្រះតេជគុណព្រះវិន័យធរ អនុគណ (ឯក-ញិម) ចៅអធិការវត្តធម្មិស្សរារាម ស្រុកសូទ្រនិគម ខេត្តសៀមរាប សូមឲ្យលោកជួយកែសម្រួលពាក្យខ្លះហើយនឹងពិនិត្យអក្សរឲ្យត្រឹមត្រូវឲ្យ លោកក៏មេត្តាទទួលភារៈដោយសេចក្ដីអនុគ្រោះ ។

សៀមរាប នៅថ្ងៃទី ១ មករា ព.ស. ២៤៩៤ គ.ស. ១៩៥២

ព្រះប្រសើរបញ្ចាង់ ម៉ុក-ទួន

នៅមន្ទីរ អភិរក្ស អង្គរ សៀមរាប

# សុភាសិត - ពាក្យប្រាំបី

*លជិគរុ កុតោវិជ្ជា លជិភរិយា កុតោបុត្តា*

*លជិភជា កុតោយសោ លជិទានំ កុតោបុញ្ញំ ។*

## (ពាក្យប្រាំបី)

អ្នកដែលខ្មាសគ្រូនឹងគ្មានវិជ្ជា អ្នកដែលខ្មាសភរិយាគ្មានកូនច្រើន
អ្នកដែលខ្មាសស្តេចគ្មានយសប្រសើរ អ្នកដែលខ្មាសធ្វើទាននឹងគ្មានបុណ្យ។
អ្នកខ្មាសការងារសាបសូន្យធនគុណ អ្នកខ្មាសហៅមុនគ្មានភ្ញៀវឡើងផ្ទះ
អ្នកខ្មាសអាហារនឹងស្វិតក្រពះ អ្នកខ្មាសមានះនឹងខូចអាត្មា ។
អ្នកខ្មាសយសស័ក្តិមិនថ្កើងអាត្មា អ្នកខ្មាសសមណនឹងខានធ្វើបុណ្យ
អ្នកខ្មាសភាសាលក់ដូរខាតទុន អ្នកដែលខ្មាសគុណនឹងខានធ្វើការ ។
អ្នកដែលខ្មាសភស្ត្រនឹងគ្មានអំណាច អ្នកខ្មាសសិស្សខ្លាចមិនហ៊ានរកហៅ
អ្នកដែលខ្មាសកូននឹងខានប្រដៅ អ្នកដែលខ្មាសខ្លៅនឹងទៅជាប្រាជ្ញ ។

(ពាក្យប្រាំពីរ)

ធម្មតាអ្នកល្អនឹងកខ្វន ត្រូវធ្វើតាមក្បួនបុរាណប្រាម
ការខុសចោលទៅការត្រូវតាម ឯការមគុណភ្ជួររំលត់ខ្វះ ។
កុំទុកបណ្ដោយឲ្យវាជេះ ក្រែងទាល់បំណោះលត់មិនល្អះ
នឹងបង់របស់អស់ពីផ្ទះ កាន់មាន៖គង់មានមនុស្សគេនិន្ទា ។
គិតអ្វីឲ្យវែងកុំបែងខ្វី សូម្បីចង់ស្រីមើលឬកពា
ផ្គាប់ស្ដេចតោងតាមព្រះទយា ផ្គាប់ភស្ដ្រដ្ឋីបគ្នាតោងមើលចិត្ត ។
ភ្ញៀវមកតោងមើលអាការៈចេញ ពោលពាក្យម្ដេចមិញគង់ឃើញពិត
ពាក្យស្មែងក្រែងស្មួតជូនដាមិត្រ ពាក្យពិតជូនពាលឝមាលវិញ ។
ពាក្យលេងជួ ពោលលប្រាជ្ញា ពាក្យគ្រៀងមុសាការគេដេញ
អ្នូតខ្លួនតោងឃ្លាតពីខ្មៅចេញ ស្រឡាញ់តោងលោមថ្នមមើលចិត្ត។
គេលើកកុំលោតទៅតាមយស បានខ្ពស់មើលទាបរក្សាមិត្រ
ដើរមុខទុកក្រោយកុំឲ្យជិត លោកប្រែតោងព្រិត្តចិត្តកុំប្រែ ។
កាន់ប្រាជ្ញកុំប្រួបសម្រួបតាម ហួសហើយកុំហាមឲ្យតាមកែ
បទខ្វីតោងវែរវៀសបែរ រៀនស្នេហ៍គាងស៊ិទ្ធចិត្តឲ្យស្ងួន ។

ប្រាក់មាននៅខ្លួនឲ្យគេខ្ចី បំណោះបេះអ៊ីនៅក្នុងក្បួន
ប្រពន្ធមាននៅឆ្ងាយពីខ្លួន ផល់ជួនត្រូវការរអាចិត្ត ។
បេះច្រើនលំបាកយ៉ាកនឹងគេប បេះតិចព្រួយប្រាណរំខានគិត
ល្ងង់ល្ងើប្រើការង្វចគេល្ងិត ឥតបើគិតមិនកើតការនោះបាន ។
តាំងខ្លួនគោងខ្លាចអំណាចពាល វែងណាស់លេចវាលហួសប្រមាណ
លក់ដូរមើលដើមឲ្យដឹងដាន គិតអានសូមធ្វើតាមបញ្ញា ។
ទូកលឿនជិះលប់ប្រយ័ត្នលិច ត្បូងពេជ្ររឹងម្តេចគង់ដែបផា
ទីស្ងាត់ប្រយ័ត្នចេញវាចា គិតការកំបាំងកុំអាងជិត ។
ភ្ញាត់មាត់មិនទប់កំពប់ប្រាក់ ភ្ញាត់ជើងៗបាកមានថ្នាំបិទ
ភ្ញាត់ការគោងតែបំបែរគិត ភ្ញាត់ចិត្តក្រចាប់ទៅតាមបេះ ។
យល់ញាតិឃ្លាតប្លាប់ចាប់វាទ យល់ការគង់ឃ្លាតឃ្លៀងចំណោះ
ដំរីជើង ៤ គង់ភ្ញាត់អេះ អកប្រាជ្ញដែលបេះគង់ភ្លាំងខ្លះ ។
ចាប់ត្រីដៃពីៈដម្រាហោម ចាក់អង្ករយកអង្កាមហោមមិនឈ្នះ
ដំរីជុះជុះតាមគង់រយះ បន់ព្រះទៅសំពះឯបាយាប ។
ស្ទៀកសសាងព្រឹត្តចិត្តនៅខ្មៅ ពោលប្រាជ្ញតាមខ្មៅចងបៀសបាប
យកវែកឲ្យដឹងរស់ប្រៃសាប យកខ្សាច់មកគាបបានប្រេងឬ? ។

ឫស្សីធ្វើក្លាក់ដាក់គ្មានថ្នាំ គងស្គរគាំងវាយមិនឮ
សុរិយាមិនយកជាពន្លឺ ជឿកាន់អំពិលអំពែកសត្វ ។
បងអ្វីមិនខ្ជាប់ស្មើសង្សារ ការអ្វីមិនស្មើការប្រតិបត្តិ
ស្ងាត់អ្វីមិនស្មើចិត្តដែលស្ងាត់ កាចអ្វីមិនស្មើសត្វមនុស្សពាល ។
ភោគអ្វីមិនស្មើនឹងភោគឃ្លាន ទានអ្វីមិនស្មើទានធម៌ទេសនា
មានអ្វីមិនស្មើមានបញ្ញា ថ្លាអ្វីមិនស្មើចិត្តជាបុណ្យ ។
រហ័សអ្វីមិនស្មើចិត្តដែលនឹក មុតអ្វីមិនស្មើទឹកដោរធន់
ធ្ងន់អ្វីមិនស្មើនឹងគុណធ្ងន់ ធនអ្វីមិនស្មើធន់ប្រពន្ធប្រើ ។
មើលមេឃគោងមើលទៅទេព ចូលព្រៃព្រឹក្សាគោងមើលលើ
យកមិត្រគោងមើលចិត្តស្មោះស្មើ យកក្មើគោងមើលឲ្យសមប្រាណ ។
ធ្វើស្រែចំការគោងមើលស្មៅ ដាក់ទុកកូនចៅមើលសណ្ដាន
ធ្វើទីលំនៅមើលភូមិស្ថាន បរិភោគប្រមាណមើលអាហារ ។
ដាវមុតៗមែននៅក្នុងស្រោម វិជ្ជាបេះព្រមមិនត្រូវការ
ស្ត្រីឥតប្ដីថែរក្សា គុជ្ជាឥតហ្មនឹងប្រជើ ។
ទឹកថ្លាតែងឯងទុកឯម្កល់ ជាតិដែកៗដុលខ្លាចដំបៅ
ត្រញ្ញងខ្លាចខ្ញូបក្លួចង្លូចស្មៅ ទូកខ្លាចគេទៅជាន់គែមផ្អៀង ។

ហោរាប្រយ័ត្នមាត់អើល ដាងទងកាន់សីលប្រយ័តទៀង
ចៅក្រមប្រយ័ត្នកុំលំអៀង អ្នកផ្ទៀងប្រយ័ត្នបាត់អក្ខរា ។
លលេងកូនក្មេងគង់អាប់យស លលេងនឹងពស់គង់ចឹកផ្សា
លលេងល្បែងអ្វីគង់គេថា លេងស្រីលេងស្រាគង់ធ្លួតចិត្ត ។
ឯស្រានឹងស្រីបនឹងល្បែង គួរលះគួរលែងកុំប្រព្រឹត្ត
ជារបស់នាំខ្វល់វល់ចិត្ត វិបរិតខូចខ្លួនក្នុងលោកីយ ។
តែថាឯស្រានឹងការល្បែង គួរលះគួរលែងបានមិនអ៊ី
ឯត្រង់បំណង់នឹងស្ត្រី លោកីយឃើញក្របើលះបាន ។
លះបានតែលោកព្រះយោគា ភាវនាចំរើនព្រះកម្មដ្ឋាន
បន្ថយក្តីត្រេកសម្រេកឃ្លាន តាំងនៅក្នុងឈានឈប់ស្ងប់អើយ! ។

*ចប់កាព្យទុកញ៉ា សុត្តន្តប្រជាឥន្ទ ប៉ុណ្ណោះ*

## សុភាសិតប្រដៅឲ្យស្នេហា

## ប្រទេសជាតិ - សាសនា - មហាក្សត្រ

រីជាតិសាសនានិងមហាក្សត្រ    បីនេះជាត់ជាគោលបូរី
សូមជនខេមរៈទាំងប្រុសស្រី    គប្បីគោរពគ្រប់អាត្មា ។
ហៃយុវជនខេមរជាតិ    ចូរខំខ្មីឃ្មាតរៀនវិជ្ជា
មិនត្រូវដើរលេងល្បែងពាលា    ដ្បិតអីភារាពឹងលើអ្នក ។
ស្រុកយើងថ្កើងយសព្រោះអ្នកនេះ    គ្រប់សព្វបំណះប្រាកដជាក់
តែបេះភីភ្លេទើទាក់    មិនដឹងរោតវត្តហៅអ្នកព្រៃ ។
ជាតិខ្មែរកុំស៊ីសាប់ឈាមគ្នា    ឃើញភក្ត្រប្រជាគួរប្រណី
ប្រយប្រាបប្រយោជន៍ដោយមេត្រី    នេះដឹងការអត្ថចរតា ។
កុំលេងបៀហ៊ោធូកំតាត់    នាំឲ្យវិបត្តិខូចកិរិយា
ខូចទាំងទ្រព្យធនយសសក្ដា    ហើយនាំសីមាឲ្យមានទោរ ។
ឯករាជ្យត្រូវប្រើតអក្សរជាតិ    ហើយលះមារយាទបរភេទា
កុំត្រាប់ពល់គោកទំមែកពោធិ    កុំសោះត្រូវនេះសព្វភាសា ។
កិច្ចការណាដែលផ្ទាល់នឹងខ្មែរ    ត្រូវតែសរសេរជាខេមរភា

ដ្បិតអីជាតិយើងខ្វះវៃនគា    កុំឲ្យសាសន៍ណាមើលងាយបាន ។
ត្រូវសាងអ្នកប្រាជ្ញនិងយោធា    ទើបរដ្ឋកម្ពុជាយើងថ្កើងថ្កាន
សាងប្រាជ្ញត្រូវប្រែក្បួនបុរាណ    ឲ្យបានមានច្រើនកុំទំនេរ ។
មិត្រអើយក្រោកឡើងដំកើងជាតិ    ខំឃ្នាតយាត្រាឲ្យទាន់គេ
ពុកប្រកដិតខាងសាងក្រោយទេ    ហេតុអ្វីក៏គេទៅមុខបាន ។
វ័យបឋមត្រូវខំរៀនវិជ្ជា    វ័យពីរឧស្សាហ៍រកធនធាន
វ័យបីសែងធម៌ទៅនិព្វាន    គឺផលសីលទាននឹងភាវនា ។
កុំកាន់ឫកខ្លួនហួសក្បួនខ្នាត    ហើយកុំប្រមាថចាស់ព្រឹទ្ធា
ជួបសង្ឃឬវត្តត្រូវវន្ទា    ជាតិខ្មែរជួបគ្នាត្រូវកាន់ជើង ។
ត្រូវខំធ្វើការដើម្បីជាតិ    កុំគិតខ្ចីឃ្លាតតែខ្លួនយើង
សាមគ្គីគ្នាឲ្យច្រើនឡើង    តែងក្បួនដំកើងកុំស្ទួនកាយ ។
ចូរខំព្យាយាមធ្វើកិច្ចការ    ហើយចេះរក្សាទ្រព្យទាំងឡាយ
កុំឲ្យវិនាសខូចខាតខ្ចាយ    មិត្រល្អសិមរាប់សុទ្ធជាគ្នា ។
ស្រុកខ្មែរពីដើមមានសេដ្ឋី    ពាសពេញបុរីច្រើនមហិមា
ឥឡូវម្តេចបាត់ពីភព    ចុះយើងរាល់គ្នារង់ចាំអី ។
ពោលអ្វីត្រូវពោលឲ្យពីរោះ    ក្នុងពោះឲ្យត្រង់តាមសំដី

បើឃើញខុសម្ដងកុំអាលស្ដី　គួរតែប្រណីដាស់តឿនគ្នា ។
ស្រុកប្កើងខ្លួនយើងខ្ពសត្រដែត　ក្រឡេកភ្នែកទៅសព្វត្រីហា
ឃើញសុទ្ធតែជនជាតិនានា　ខ្មែរកម្ពុជាតើធ្វើអ្វី ។
មនុស្សខ្មៅស្អប់ប្រាជ្ញខ្លាចកុសល　អ្នកមានយោបល់ខ្វល់នឹងស្រី
ខ្លួនដេកក្នុងភក់លក់ផែនដី　ទាំងបីនេះជិង្គត់ស្រុកពិត ។
កុំប្រកាន់យសក្រៅជម្រា　នៅទស្ថានណាត្រូវកានក្រិត្យ
កុំធ្វើបំពានទៅតាមចិត្ត　ច្បាប់ព្រៃកុំស្និទ្ធលះឲ្យឆាប់ ។
បើគេមិនក្រាបវររន្ទា　កុំក្រេវក្រោធខុសសណ្ដាប់
ទោះបីប្រដៅឬប្រាយប្រាប់　ត្រូវតែកាន់ច្បាប់កុំវាយជេរ ។
កើតមកជាមនុស្សក្នុងលោកីយ　គិតអ្វីឲ្យវែងកុំប៉ៅឡៃ
នៅក្រោមទង់ជាតិប្រាសាទដែរ　គួរគិតកែប្រែចិត្តចាស់ចេញ ។
ឈ្មោះផ្លូវឬមន្ទីរភានា　យីហោត្រីហាលក់ទំនិញ
គួរតែសរសេរជាខ្មែរវិញ　ទើបស្រុកយើងពេញយសសក្ដា ។
រីជាតិសាសនានឹងមហាក្សត្រ　ជាខ្ទមសម្បត្តិកម្ពុជា
ចូរខេមរជនទាំងអស់គ្នា　គោរពបូជាកុំឲ្យហ្មង ។
ស្លាប់គាប់ជាងរស់នៅខំគេ　កុំចាំគិតគ្នេរឲ្យច្រើនផង

ឯករាជ្យប្រទេសឯកកន្លង រក្សាចាំបងកុំកន្តើយ ។
ខ្លឹមសារបណ្ដូលត្រកូលចិត្ត ឥស្សរភាពពិតណាអ្នកអើយ
បបួលគ្នានាំឡើងដល់ត្រើយ កុំធ្វើតោះតើយឲ្យខូចបង់ ។
ស្វាមីជាគោលនៃពួកស្ត្រី ក្សត្រផែនដីជាគោលនៃមហាជន
សំបៃជាគោលអ្នកមានធន ប្ដីប្រពន្ធជាគោលនៃសង្សារ ។
អក្សរជាគោលរបស់ជាតិ វិន័យលោកនាថជាគោលសាសនា
អំណាចជាគោលមហាក្សត្រា សព្វគ្រប់វិជ្ជាជាគោលកាយ ។
អ្នកប្រាជ្ញមិនត្រូវវក់ក្នុងកាម គប្បីធ្វើតាមក្រិត្យប្រាជ្ញប្រាយ
បំពេញប្រយោជន៍វឌ្ឍទាំងឡាយ បន្ថយកាមកាយកុំស្រេកឃ្លាន ។
វិជ្ជាវិសេសលើសទ្រព្យធន ចោរមិនអាចប្លន់លួចយកបាន
វិជ្ជាគ្មានថ្លៃនឹងប្រមាណ ប្រើចេះតែបានគ្រប់វេលា ។
ប្រទេសផ្ញើដោគលើគំនិត បើមិនចេះគិតគង់វេទនា
កុំសង្ឃឹមអ្នកបុណ្យជួយគាំពារ ក្រែងជាប់វេភនល់ផែនដី ។
ត្រូវចងមិត្រនឹងមហានគរ អាចជួយគាំទ្រព្រះបូរី
កុំចងតែប្រទេសតីរបី ទើបបានផែនដីយើងថ្លាថ្លៃ ។
ស្រុកខ្មែរពីដើមបានចងមិត្រ នឹងស្រុកឆ្ងាយជិតច្រើនពេកក្រៃ

ទើបបានស្រុកក្តៅឡើងស៊ីវិល័យ   សព្វថ្ងៃគួរបេះបងមេត្រី ។
ស្រុកណាមនុស្សតិចរិទ្ធិអំណាច   គេឥតកោតខ្លាចក្រែងបារមី
ហេតុនេះសូមជនខ្មែរប្រុសស្រី   ជួយផ្តល់ផែនដីកុំឲ្យខាន ។
នារីជាអ្នកបង្កើតវង្ស   គួរផ្តល់អត្តភាពឲ្យសុខសាន្ត
កុំធ្វើមារយាទដូចតិរច្ឆាន   ដើរលក់ដូរប្រាណខូចពង្សា ។
ជាតិខ្មែរកាចបានតែគ្នាឯង   ត្រង់ជាតិគេក្រែងខ្លាចដូចខ្លា
ច្រើនតែអំនួតកាន់ឫកពា   ហើយធ្វើកិរិយាដូចជ្រូកស្រុក ។
មិត្រអើយត្រូវមានប្ដីប្រពន្ធ   កុំបីអត់ធន់ខុសក្រមក្រឹត្យ
ជួយបំរើនជាតិដោយស្វាលស្និទ្ធ   ជាងមេត្រីចិត្តកុំបាចសាច ។
មានកូនប្រពន្ធនឹងទាសា   ប្រព្រឹត្តកិរិយាក្រោមអំណាច
ឲ្យបេះសន្តោសនឹងកោតខ្លាច   អ្នកនោះអាចបានសុខពេញពោ ។
អ្នកលប់គុណគេតែងមានគ្រោះ   ឯអ្នកក្តួតយសតែងឡើងដោរ
ជនខ្ជិលតែងខ្លាចច្រើនពះពោ   ពាលឡើងជនោរតែងស្លាប់ប្រាណ ។
កុំសេពនឹងជនអកតញ្ញូ   កុំសេពនឹងគ្រូឥតបំណាន
កុំទុកចិត្តជនពោលភូមិស្ថាន   បើចង់កើតកានត្រូវផ្គងរិទ្ធិ ។

ជនល្ងង់លង់ខ្លួនព្រោះស្ងួនកាយ
អ្នកខ្លាចអន្តរាយតែងប្រយ័ត្ន
ប្រុងប្រាណជិបត្រដើររឿបសត្វ
តែងគ្មានវិបត្តិដល់អាត្មា ។
ភជរថវៀរកង់ទៅមិនបាន
ខ្លួនប្រាណតែងជាប់ដោយវាសនា
ភ័ព្វព្រេងសំរេចព្រោះឧស្សាហ៍
ជនឥតប្រាជ្ញាបុណ្យមិនមាន ។
គ្រោះថ្នាក់ដល់អ្នកនឹងគេចរួច
ចោរឃេញបើល្ងួចមនបោលដាន
ប្រមាទនាំខាតខូចភូមិស្ថាន
ប្រយ័ត្ននាំបានសុខសាន្តកាយ ។
កាលណាបើស្រុកសុខក្សេមក្សាន្ត
ពួកជនគ្រប់ស្ថានបានសប្បាយ
ត្រូវតែកែខ្លួនពីអនរាយ
ប្តូរជនទាំងឡាយសាងរិទ្ធិខ្ពស់ ។
ជន ខ្លៅច្រើនអួតថាខ្លួនប្រាជ្ញ
ជនឥតអំណាចអួតស័ក្តិយស
បណ្ដាលច្រើនអួតការទាស់ឈ្លោះ
ពាក្យពីរោះនាំឲ្យគេគួបចិត្ត ។
សំដីអ្នកតូចត្រូវយ៉ាងណា
តែងពោលថាខុសទាស់គំនិត
អ្នកធំទុកជាពោលមិនពិត
កំគង់បះចិត្តជឿហ្មត់ចត់ ។
ជនពាលស្អប់ប្រាជ្ញខ្លាចក្តីត្រូវ
បើឃើញមិនសូវបេះប្រាកដ
កុំចង់ប្រកែកព្រេងព្រិលមាត
តែភ្លាត់គងខ្លាសអ្នកប្រើ ។
អ្នកខ្ជាក់បានយសខ្ពស់ឡើងវាក់
អ្នកឥតមាសប្រាក់ធ្វើសេដ្ឋី
អ្នកខ្លៅធ្វើប្រាជ្ញប្រុសធ្វើស្រី
អាចញុំាងផែនដីឲ្យក្រឡាប់ ។

រៀបវន្តដំបូងតែងលំបាក កុំឈប់សម្រាកកុំប្រញាប់
កុំបោលទុកយូរហួសពេកស្លាប់ អំបិលសម្រាប់ធម៌សច្ចៈ ។
កុំកាប់បំពង់រង់ទឹកភ្លៀង ធុរៈណាទៀងត្រូវកុំលះ
រៀនសូត្រកុំលោតបោលមានៈ បើមានគេជះត្រូវលះស្រី ។
កុំថ្កោលទោសគេពុំពិនិត្យ កុំគិតខ្លួនឯងជាប្រពៃ
កុំធ្វេសប្រហែសពាក្យសំដី នាំឲ្យមានភ័យដល់អាត្មា ។
កុំអួតថាឯងចេះជាងគេ កុំធ្វើរៀបរវើងកិច្ចការ
ធ្វើអ្វីកុំបោលពិចារណា ទើបបានហៅថាពិតជាប្រាជ្ញ ។
កិច្ចការណាដែលគិតក្នុងចិត្ត ត្រូវតែបាំងបិទកុំបាចសាច
បើឃើញការណាប្លែកអង់អាច ពោលដែកប្រាប់ប្រាជ្ញឲ្យបានល្បី។
គំនិតផុតពួកមហាជន មេចុនផុតចិត្តសត្វលោកីយ៍
កុំណាញ់តែងផុតចិត្តស្រីៗ កុំដោរស្នើផុតស្រីភព ។
កុំបីឡើងចុះលុះលោកធម៌ កាន់ចិត្តឲ្យល្អស្លូតរាបទាប
កុំឈ្លក់ខ្លួនជ្រុលពុលទំងលាភ កាន់ចិត្តស្លូភាពយុត្តិធម៌ ។
មានភ្លៃកល្អជាតែដូចខ្លាក មានមាសប្រាក់តែដូចជាក្រីក្រ
បៀតបៀនសត្តនដោយកាំសរ និករបែបនេះទុកដូចពស់ ។

ត្រូវខំធ្វើការសព្វសារពើ　　កុំនៅធ្វើខ្ជិលនឹងអាប់យស
សំអាតមន្ទិលអសប្បុរស　　ត្រូវបោះប្រូហើងបែកកូនចៅ ។
ត្រូវតែភប់អានជាតិខ្លួនគ្នា　　ខំរៀនវិជ្ជាបំបាត់ខ្លៅ
លះគ្រឿងទុច្ចរិតចិត្តហ្មងសៅ　　អ្នកក្រៅជួយទុក្ខញាតិពីសី ។
កាល់ក្រមកតែពីកំជិល　　នាំឲ្យរេចរិលអ័ព្ទសួស្តី
ហេតុនេះបូរជនទាំងប្រុសស្រី　　ខិតខំឃ្លាតខ្ចីរកទ្រព្យ ។
ដង្ហើមចេញចូលកុំឲ្យខាត　　ត្រូវខំសង្វាតរៀនវិជ្ជា
ផ្ទៃខួរក្បាលយើងគ្រប់វេលា　　ខំប្រឹងភាវនាភាលយប់ថ្ងៃ ។
បើឥតមាតាក្នុងគ្រឹហា　　មានតែភរិយាកាចបង្រៃ
ត្រូវគេចទៅនៅក្នុងព្រៃផ្សៃ　　ព្រោះផ្ទះបង្រៃគួរខ្លាចណាស់ ។
កូនក្មេងមិនបានរៀនវិជ្ជា　　គេតែងនិន្ទាដល់ពួកចាស់
បើរៀនមិនបានចេះដាក់ច្បាស់　　គេតែងជៀលត្ថះជាគ្រូខ្លៅ ។
រៀនសូត្រកុំភាន់បន្ទាន់ញាប់　　ស្វែងទ្រព្យសន្សំកុំខំខ្លាំង ។
ឡើងភ្នំសន្សឹមកុំប្រណាំង　　សេពកាមតិចៗតាមកំលាំង
ស្ដាប់គិតសួរកត់គោលវិជ្ជា　　សិល្បសាស្ត្រនានាខ្មែរបារាំង
ចូរគិតខ្មាសគេកុំធ្វើខ្លាំង　　ត្រូវតាំងចិត្តនៅជាកណ្ដាល ។

មិត្រអើយបើជាតិរបស់យើង បេះគ្រប់គ្នាឡើងទើបបានស្រាល
ស្រួលនឹងពន្យល់ការត្រកាល កើតក្បាលនៃជើងបិមយើងដើរ ។
លែងខ្ជិលដេកដឹកក្នុងដំណើរ ព្រោះខ្លាំងក្រានបើបានអាហារ ។
វង្សខ្មែរមានដោតបុះតែបេះ បើខ្វះបំណេះធ្វើការងារ
មិនងាបេណោះខ្លួនជាអ្នកជា នាំកើតវេទនាព្រោះគ្នាឯង ។
បែកសាមគ្គីឃាតវាតឆ្ងាយ ប្រទូសរ៉ាយគ្នាគួរឃើញស្តែង
ចូរស្តាប់ភាសិតហើយគិតវែង ដូចបានសំដែងមកនេះហោង ។

## ពាក្យ ៨

ខំរៀនសូត្រឲ្យបានជាអ្នកប្រាជ្ញ ចិត្តអងអាចស្រឡាញ់កិត្តិយស
ខំប្រឹងប្រែងស្ទួយស្រុកឲ្យខ្ពង់ខ្ពស់ កុំបីឈ្លោះប្រកែកបែកចិត្តគ្នា ។
ស៊ូរតែស្លាប់កុំឲ្យបង់ក្តីគាប់ ស៊ូបង់ទ្រព្យកុំឲ្យបង់ភាថា
ស៊ូរបង់ពាក្យកុំឲ្យបង់សត្យា ស៊ូមរណាកុំឲ្យបង់ក្លាហាន ។
កុំគិតឆ្ងាញ់តែបុណ្យរៀងតាមព្រេង ក្រែងអសុរលើងធេងពីភូមិឋាន
កសាងអាវុធនាំឲ្យក្មេងក្សាន្ត ឲ្យស្រុកយើងបានថ្កើងដោយសិរី។

រម្ងាប់ជនកំណាចដោយប្រហារ រម្ងាប់មិត្រឧបការដោយកុំស្តី
រម្ងាប់ស្រីដោយកុំឲ្យទ្រព្យអ្វី រម្ងាប់ភគដោយកីបន្ថយបាយ ។
ហៃមិត្រអើយត្រូវតែកែខ្លួនអ្នក កុំស្មោះស្ម័គ្រនឹងល្បែងផងទាំងឡាយ
ល្បែងតែងតែនាំឲ្យអន្តរាយ សូមប្រុសស្រីទាំងឡាយចៀសគ្រប់គ្នា ។
ប្រាជ្ញឯណានៅរួមដោយសិស្សកាច ឬប្រពន្ធកំណាចពោរមាយា
នឹងអសប្បុរសជាតិពាលា ទោះប្រាជ្ញជាក៏គង់លង់មិនលែង ។
ឃើញខ្លាក្រាបកុំថាខ្លាសំពះ ឃើញខ្លាទះកុំថាខ្លាប្រឡែង
ឃើញខ្លាស្ងួមកុំថាខ្លាខ្លាចឯង ត្រូវប្រយ័ត្នក្រែងលង់ខ្លួននាំភ័យ ។
បើនឹងមើលកុំ មើលដោយនេត្រា ត្រូវមើលដោយប្រាជ្ញាទើបប្រពៃ
បើនឹងស្តាប់ត្រូវស្តាប់ដោយញាណញេយ្យ កុំព្រមជឿសំដីគេផ្កាប់មុខ ។
ទានជាថ្នាំនាំកើតក្តីស្នេហា កំណាញ់ជាឧសថនៃទោសទុក្ខ
ទានជាថ្នាំយសសក្តិចំរើនសុខ កំណាញ់ទុកជាថ្នាំនាំកំព្រា ។
សត្វទាជាប់ទ្រុងខំបម្រះ តែងតែប្រទះទុក្ខដល់កាយា
ទុកជាមិនបានរួចដូចប្រាថ្នា អ្នកប្រាជ្ញថាជាកិច្ចនៃមនុស្សល្អ ៖
កាលបើឃើញថាសាចមិនបានស៊ី កុំសំភីយកឆ្អឹងមកព្យួរក
កុំជឿខ្លាំងថាចិត្តវាស្មោះសរ ដូចខ្លាកម្រនឹងអភ័យទោ ។

សម្បត្តិសម្រាប់អ្នកដែលឥតប្រាជ្ញ យសសក្តិអំណាចសម្រាប់អ្នកល្ងង់ខ្លៅ
បើជាតដៃដែលឥតមានដំបៅ តើថ្នាំពិសផ្សាបទៅដូចម្តេចបាន? ។
កុំចង់ធំមុនពេលមានបំណេះ កុំចង់បេះមុនពេលមានបំណាន
ធយសសក្តិនោះមានគេរាប់អាន ក្រពះធំនោះគ្មានគេរាប់ណា ។
បើទាញគេទាញដោយកំលាំងកាយ ត្រូវខ្វល់ខ្វាយកុំឲ្យទាញវាចា
បើកំលាំងសំដីទាញកាលណា ត្រូវរក្សាចិន្តាឲ្យប្រពៃ ។
អ្នកមានមាត់ហើយមិនបេះគរ៉ា អ្នកមាននេត្រាមិនបេះមើលអ្វី
អ្នកមានត្រចៀកមិនស្តាប់សំដី ពួកជនទាំងបីនេះហៅស្លាប់ពិត ។
បើនឹងទន់កាយកុំទន់សំដី បើនឹងភ័យកុំតែភាន់គំនិត
បើលង់ខ្លួនស្លាប់ៗ ចុះកុំគិត បើនឹងចង់រិតៗចុះកុំរួត ។
ដោតវិសនាម្តេចមានដល់មនុស្សខ្លៅ ញាតិក្នុងក្រៅម្តេចមានដល់អ្នកក្រោធ
ប្រាជ្ញាញាណម្តេចមានដល់អ្នកឆោត អ្នកជាក់ដោតម្តេចមានពាក្យសត្យា ។
សាលារៀនទុកដូចជាឪពុក វិទ្យាសាស្ត្រទុកដូចជាមាតា
វិរិយៈទុកដូចជាអ្នកសិក្សា គ្រូប្រាជ្ញាទុកដូចជាពានគ្រូ ។
អត់ធន់បាបបានមានគេកោត អត់ធន់ឆោតបានគ្មានគេឲ្យពរ
អត់ធន់ឃើញធម៌មានគេសាទរ គ្មានអត់នាំវរវីកដូចតិរច្ឆាន ។

បើមានមាត់ដែរតែមិនតវ៉ា    តើមានអ្នកណាតជួសខ្លួនបាន
បើមានចិត្តដែរតែមិនក្លាហាន    តើឲ្យប្រាណបានខ្ពស់ដូចម្ដេចលន់
បើមានអង់អាចនឹងធម៌ខន្តី    លែងភិតភ័យអ្វីនឹងភារៈធ្ងន់
វាជាពីរោះឬមួយទន់ភ្លន់    ភ័យអ្វីនឹងជនជាតិវៀងណាន ។
ដៅពង្សអ្វីមិនស្មើនឹងវិជ្ជា    សត្រូវអ្វីដោយព្យាធិមិនមាន
កំណាប់អ្វីមិនស្មើនឹងបុណ្យទាន    ធនធានអ្វីមិនស្មើនឹងប្រាជ្ញា ។
រុក្ខជាតិដែលគេដាំក្នុងផើង    តែងតូចស្ដើងដោយមាឌនឹងផ្លែផ្កា
ផើងគឺមនុស្សជាខ្នាំងយើងរុក្ខា    មិនឲ្យល្អតទៅណាបានធំហួស ។
ផ្ទះធ្លុះលេចគេអាចជួសជុលបាន    ប៉ុះសន្តានធ្លុះលេចមានអ្វីជួស
ជនកំជិល ជកផ្សងសំណាងហួស    កុំជ្រលួសរកបុណ្យជួយបាត់បែង ។
សុខទុក្ខកើតមកតែពីការធ្វើ    សព្វសារពើមិនដែលកើតឡើងឯង
បើនៅស្ងៀមតើកម្មអ្វីតាក់តែង    កុំចង្អែងដេកស្រែករកអ្នកបុណ្យ ។
ទុកជាព្រះរយពាន់ជួយមិនបាន    កាលបើប្រាណកំជិលដេកតែបន់
អ្នកជឿខ្លួនៗឲ្យជួយទាន់ហន់    អ្នកជឿបន់ៗជួយឲ្យទុក្ខា ។
គ្មានអ្នកណាជួយខ្លួនជាងខ្លួនឯង    គ្មានកម្មអ្វីតាក់តែងជាងសិក្សា
គ្មានជោគអ្វីប្រសើរជាងប្រាជ្ញា    គ្មានវាសនាអ្វីស្មើដៃមិនស្ងៀម ។

ចង់បានៗប្រែងទៅយៗខ្ជាប់មកគាប ចង់បានលាភទៅបន់ឯទេពសៀម
ចង់បានសុខទៅបន់អ្នកតាសៀម អ្នកនោះទៀងតែគ្មានបានសុខា ។
អ្នកដែលរំលឹងកុំនឹងអ្នកប៉ុះ ទាំងពីរនេះខុសលើអ្នកខាងណា ?
ប្រសិនបើមានខ្មាំបាំភោក្តា តើអ្នកណានឹងរួចគ្រោះអត្តភាព ។
ប្រទេសណាដែលភាសាជាតិស្លាប់ តែងនឹងអាប់ក្នុងលោកជាដរាប
ទីណាពេញទៅដោយធម៌លុតក្រាប ទីនោះជុនជាប់ត្រូវឆាបលះបង់ ។
ក្នុងទីណាដែលយុត្តិធម៌ស្លាប់ ត្រូវប្រញាប់ដើរចេញកុំបង្អង់
ទីណាដែលឥតអ្នកចិត្តទៀងត្រង់ ត្រូវលះបង់ទីនោះឲ្យយ៉ាងឆ្ងាយ ។
ព្យាយាមទុកជាបុណ្យពីអតីត គំនិតជាដោតខែឆ្នាំទាំងឡាយ
ល្អអាក្រក់កើតមកពីកម្មកាយ ថ្ងៃខែឆ្នាំប្រាយប្រាប់ទិសទីជិន ។
បើធ្វើបុណ្យត្រូវកុំធ្វើធ្វេចភ្លេក បើលើកត្រូវស្មានមើលទម្ងន់
បើនឹងជួញត្រូវមើលប្រមាណទុន រៀនវេទមន្តត្រូវចិត្តជឿរំពោះ ។
កុំធ្វេចភ្លេកស្រែកបែកសាក្នុងពាង កុំអាលរាងមុនពេលដែលមានគ្រោះ
កុំអាលជាមុនពេលដែលប្រល្មោះ កុំអាលទាស់មុនពេលពិចារណា ។
ខ្ជិលច្រអូសនាំឲ្យខូចការងារ ឥតទ្រព្យនាំឲ្យខូចប្រាជ្ញា
ការខ្ជះខ្ជាយនាំឲ្យខូចវង្សា ឥតមេធានាំឲ្យខូចមារយាទ ។

ឥតគួរសមនាំឲ្យខូចមិត្រភក្តិ    ឥតចិត្តស្ម័គ្រនាំឲ្យរលាយជាតិ
ឥតសាមគ្គីនាំឲ្យកើតគ្រោតគ្រាត    ខូចអស់ញាតិព្រមទាំងជនតូចធំ។
ស្តាប់ពាក្យភាសិតដែលលោកថែងចង តែងតាមបំណងសម័យនិយម
ក្រែងពាក្យត្រង់ណាខុសការមិនសម សូមជួយកែខ្ញុំកុំខ្លាចឡើយហោង។

## ពន្យល់ឲ្យនាំកូនចូលរៀន

### ពាក្យ ៧

ជាតិអើយគិតលោកសព្វថ្ងៃ    កុំគិតសង្ស័យត្រូវសង្កាត
រៀនគ្រប់បំណេះឲ្យដល់ខ្នាត    កុំឲ្យប្រមាទការសិក្សា ។
មានកូនអាយុ ៦ ឆ្នាំ    កុំចាំមេឃុំដាសតឿនចាំ
នាំកូនចូលទៅកាន់សាលា    រាជការបម្រុងកន្លែងស្រាប់ ។
មានតុកៅអីឲ្យអង្គុយ    ក្បាលម៉ីរង្គុយគ្មានសុះស្អាប់
ប្រៀនទាំងផែនទីទាំងសាវតារ    ដល់ពួកកុមារដែលនៅល្ងង់។
ការរៀនមានព្រះរាជប្រកាស    ព្រះករុណាត្រាស់ឲ្យបម្រុង
ដល់ឆ្នាំចូលរៀនកុំបង្អង់    តែទុកការង់ត្រូវមានទោស ។
ជាបទលហុដល់មេបា    ដែលស្នេហាកូនហើយសន្តោស

សណ្តាប់ខុសច្បាប់ត្រូវមានទោស　កុំសន្តោសកូនហួសមាត្រា ។
ហ្នឹងហើយមេបានាំឲ្យខូច　ដល់ត្រកូលពូជពង្សវង្សា
ដែលកូនកើតមកក្នុងលោកា　ត្រូវមេបានាំរៀនចំណេះ ។
បើមិនចង់ធ្វើជាមន្ត្រី　ចង់រកស៊ីអ្វីត្រូវតែចេះ
ដឹងកលស្គាល់កិច្ចល្បិចជម្រិះ　រកស៊ីត្រូវចេះក្បួនការងារ ។
ទើបនាំខ្លួនជាអ្នកមានទ្រព្យ　មានកេរ្តិ៍ឈ្មោះគាប់នឹងភជការ
ល្បីឈ្មោះផ្សាយពេញរដ្ឋខេមរា　ទាំងចាស់កុមារស្គាល់ពូជពង្ស ។
បើបានចូលរៀនសាលាហើយ　កុំធ្វើកន្តើយគោងប្រាណប្រុង
ប្រឹងរៀនឲ្យបានចេះពេញវង្ស　ចិត្តកុំគិតចងឃ្វាលក្របី ។
មេបាត្រូវស្តីថាដាស់តឿន　ជម្រុលជម្រឿនជាប្រក្រតី
ព្រោះក្មេងនៅខ្ចីឆៅសេចក្តី　ពុំទាន់ដឹងអ្វីងាកោះត្រើយ ។
កុំឲ្យបណ្តោយតាមចិត្តក្មេង　ដែលវាចង់លេងនោះសោះឡើយ
វះឈប់នៅផ្ទះខ្លួនព្រងើយ　ផ្សំនឹងវាហើយចេះកាលណា ។
បើកូននិយាយពាក្យត្អូញត្អែរ　ប្រាប់ឪប្រាប់ម៉ែកុហកថា
គ្រូនេះកាចណាស់ជេរផ្តាសា　វាយដំអាត្មាតែសព្វថ្ងៃ ។
ចាស់ឆោតល្ងោតជឿសំដីក្មេង　ដែលវាចង់លេងមិនសង្ស័យ

ស្រាប់តែខឹងចិត្តពោលសំដី ល្ហើយរៀនធ្វើអីនៅផ្ទះទៅ ។
បើមិនបានបេះវាហើចុះ នៅគ្រាន់សាបព្រោះធ្វើស្រែស្រូវ
អញតាំងពីក្មេងលុះឥឡូវ ធ្វើស្រែលក់ស្រូវគង់បានប្រាក់ ។
គិតនេះខុសទេឪចស្អប់កូន សូមឲ្យតាឌូនជួយពញ្ញាក់
ត្រូវតែប្រាប់វាឲ្យដឹងជាក់ ធម្មតាលោកអ្នកធ្វើជាគ្រូ ។
មិនដើរវាយសិស្សឲ្យខូចទេ ចង់ឲ្យគេជាតាមគម្រូ
ប្រៀនឲ្យបេះឆាប់មិនចង់យូរ ហ៊ឹងហើយហៅគ្រូប្រដៅសិស្ស ។
បើគ្រូមិនដើរមិនប្រដៅ បណ្ដោយតាមទៅបានចិត្តទ្រិស្ដិ
ដើរលេងមិនរៀនគ្មានគេធ្វើស នាំឲ្យខូចសិស្សខកខាតខាន ។
ត្រូវតែប្រាប់កូនតាមបែបហ៊ឹង ឲ្យដឹងស្គាល់ផ្លូវការទន្ទាន
កុំតាមចិត្តក្មេងនាំបំពាន បើមិនខំរៀនបេះពីណា ។
បើល្ងង់យ៉ាងណាគង់បេះខ្លះ ដោយសីលតបះដែលសិក្សា
គេទុកជាអ្នកមានប្រាជ្ញា បានរៀនសាលានឹងគេនោះ ។
ឯខ្លួនអ្នកធ្វើជាមេបា បើកូនសិក្សាមានកេរ្តិ៍ឈ្មោះ
គង់តែគេកប់អានស្ម័គ្រស្មោះ នឹងមានកេរ្តិ៍ឈ្មោះពេញស្រុកខ្មែរ ។
ជាន់មុនគេចេញពីសាលា ប្រឡងបានសញ្ញាប័ត្រអ៊ូអែ

ខ្លះធ្វើជាជីខាងបកប្រែ　　ខ្លះបែរធ្វើជាគ្រូបង្រៀន ។
ខ្លះឥតបានជាប់សញ្ញាប័ត្រ　　ធ្វើការច្រើនក្ដាត់ដោយគេរៀន
ខ្លះធ្វើជំនួញលក់ព្រៃខៀន　　គេឥតខ្មាសអៀនព្រោះចេះការ ។
ខ្លះទៀតធ្វើស្រែដាំដំណាំ　　ដោយគេចេះចាំពីសិក្សា
របស់ថោកថ្លៃនៅស្រុកណា　　គេចេះភាសាដឹងឥតសល់ ។
គេធ្វើការអ្វីសុទ្ធតែច្រើន　　ចំរើនកើនឡើងដោយបានផល
ដោយហេតុគេចេះដឹងកិច្ចកល　　បានរៀនដល់ហើយស្គាល់ជើងការ ។
មានខ្លះនិយាយពាក្យត្ញត្អែរ　　កូនយើងអ្នកស្រែគ្មានប្រាជ្ញា
ចូលរៀនមិនបានក្នុងសាលា　　នាំខូចខាតការអាសាបង ។
និយាយនេះខុសព្រោះល្ងង់ខ្លៅ　　ប្រាជ្ញាមិនជ្រៅចិត្តមិនចង
ខ្ជិនជាមេបានជាល្ងង់　　មានតែគេចង់ឲ្យកូនចេះ ។
បើមិនយល់អ្វីមើលសត្វ　　គេបង្ហាត់គោក្របីសេះ
សព្វសត្វឯទៀតឲ្យបានចេះ　　ឲ្យមានចំណេះប្រើការបាន ។
ដឹងស្គាល់ឆ្វេង ស្ដាំសព្វសារពើ　　ធ្វើតាមបង្គាប់ម្ចាស់ប្រើប្រាណ
ឲ្យអូសរនាស់នង្គ័លយាន　　ជួយរកធនធានព្រោះវាចេះ ។
ចំណង់បើមនុស្សដឹងស្គាល់ស្រាប់ គ្រូប្រាប់ប្រដៅឲ្យជំរិះ

រៀនទៅម្រាំណាក៏មិនបេះ　　　កុំតែប្រហែសខ្ជិលសិក្សា ។
ហេតុនេះត្រូវកុំភ័ន្តសារតី　　　ហើយកុំគិតខ្ជិលខ្លាចសាលា
ត្រូវស្រឡាញ់រៀនស្ដាយអាត្មា　　　ឲ្យមានវិជ្ជាការចំណេះ ។
ចូរគិតខ្មាសជាតិសាសន៍នានា　　　គេមានវិជ្ជាមានតម្រិះ
យើងកុំរៀនតែនៅស្រុកនេះ　　　ទៅគ្រប់ប្រទេសផងនានា ។
ឯងរៀននៅតែក្នុងស្រុក ទ　　　ម្ដេចឡើយរិះគិតរួញរា
ឲ្យមានវល់ផល់ភ្ញាក់ងារ　　　ឃុំគេហៅរកយកទើបបាន ។
មានមេបាខ្លះគេចកែខៃ　　　ថាខ្ញុំខ្វះដៃជើងខ្លួនប្រាណ
ទុកឲ្យពាប្អូនមើលភូមិស្ថាន　　　ជួយឲ្យបានក្សាន្តមួយគ្រាសិន ។
ខ្លះថាកូនឈឺកូនតូចពេក　　　ខ្លះអួតដើកក្រនៅខ្ញុំបិន
ខ្លះថាចាំមានទោអាវសិន　　　លុះមេឃុំកិនខ្លាំងទើបខ្លាច ។
ខ្មែរអើយជាតិយើងនៅល្ងង់ខ្លាំង　　　កាន់ភាំងក្នុងការរៀនធ្វើប្រាជ្ញ
ខ្ជិលណាស់ក្នុងការសាងអំណាច　　　ភ័យខ្លាចក្រែងកូនឆ្ងាយសំនៅ ។
ការរៀននេះគ្មានកំណត់ទេ　　　ឲ្យតែបានបេះដឹងខ្លះទៅ
បើខ្លាចក្រែងកូនបានបេះជ្រៅ　　　រៀននៅសាលាមួយក៏បាន ។

អ្នកនាំថ្លិបដិកផ្តែបុះទឹក ទង់ទាញវិកផើងផ្ទេងប្រាន
ទៅមុខទៅក្រោយៈម្តបគង់បាន លាងជុំសខ្លួនប្រាណស្អាតសេង់ ។
ជំនាន់យើងនេះមានវិសនា ដោយបានវាជការធ្លូយទាញទង់
ទំនុកបំរុងហើយផ្ចិតផ្តង់ ផ្លូវប្ញេះត្រូវប្រុងប្រាណកល់គ្នា ។
បើឲ្យកូនរៀនត្រូវទំនុក កុំទុកលែងចោលដោយវេត្ត៉
សង្ឃមលោកសង្ឃជាបិតា បិញ្ចឹមឯណារស់ច្រើនម៉្លេះ ។
លោកសង្ឃរស់ដោយសារទានគេ បើយើងជាមេជាមិនបេះ
បិញ្ចឹមកូនខ្លួនរៀនបំណេះ តើលោកណាបេះបិញ្ចឹមជួស ។
បើគ្រាន់តែពឹងទឹកខ្លែង ជ្រកនៅគួរក្រែះបិត្តអ្នកបួស
តែពឹងជ្រុលណាស់ក្រែងលោជ្រួស បង់បួសជួបលោកខកខានរៀន ។
លោកសង្ឃខំផ្ចង់ត្រែសិក្ខា មានពេលឯណាមកប្រិតប្រៀន
ប្រដៅកូនគេឲ្យខំរៀន គួរអៀនកុំអែបផតបើគិត ។
បើឲ្យទៅនៅវត្តលោកសង្ឃ រៀនសូត្រដោយបង់បេះប្រព្រឹត្ត
ផ្លូវលោកផ្លូវធម៌ឲ្យល្អពិត ត្រូវមានគំនិតជួយឧបត្ថម្ភ
ផ្ចិបយើងដាំឈើប្រាថ្នាផ្លែ ត្រូវយើងខំថែដើមដែលដាំ

ដាក់ជីស្រោចទឹកតាមដំណាំ ទំនងដំណាំនេះនឹងបានផ្លែ ។
មិត្រអើយស្ទុះក្រោកឡើងទាន់ព្រឹក ខំស្រែករំឭកជនជាតិខ្មែរ
ខំខ្មាសគេណាស់ព្រោះខ្មែរជេរ ត្រូវខំកែប្រែជាតិជាថ្មី ។
កូនចៅយើងមានកុំឃ្លានប្រើ ត្រូវឲ្យដើររៀនទាំងប្រុសស្រី
ស្រុកជិតស្រុកឆ្ងាយកុំគិតអ្វី មានពេទ្យបីបាច់ថែរក្សា ។
ត្រូវបំបែកគ្នារៀនចំណេះ ឲ្យបានចេះគ្រប់សព្វវិជ្ជា
ជាងឥដ្ឋជាងឈើជាងនាវា ជាងគូររចនាចំរូបគំនូ ។
រៀនខាងវិជ្ជាធ្វើគ្រឿងយន្ត បើកបរហោះសទាន់តាមសម័យ
វិជ្ជាស្ដាប់មើលក្នុងទឹកដី ពេទ្យឆ្មបប្រុសស្រីសម្រាប់ស្រុក ។
កុំស្រប់ហើបគួចតាមគេជាក់ កុំស្ទុគ្រដោយស្មានថាស្រណុក
កុំស្រណោះស្រីស្រឡាញ់ស្រុក កុំស្រុះគ្នាទុកល្ងង់តពូជ ។
ចូរខំប្រដៅកូនចៅយើង កុំឲ្យកាន់ជើងនាំកូនខូច
ហើយកុំប្រជិតកុំប្រជួច ពូជខ្មែរគង់តែនឹងបានថ្កើង ។
បើជាតិចេះយើងត្រូវទំនុក ការអ្វីគ្រប់មុខពឹងជាតិយើង
កុំពឹងជាតិគេពេកមិនថ្កើង ឈើជើងកាលណានឹងធំបាន ។
មិត្រអើយចូរចាំបណ្ដាំខ្ញុំ ទាំងតូចទាំងធំគ្រប់ៗប្រាណ

ត្រូវប្តូរទំនៀមឲ្យបេះបាន ស្មើមុខគ្រប់ស្ថានពេញរដ្ឋខ្មែរ ។
បេះហើយត្រូវធ្វើការឲ្យជាតិ ជួយជិបមារយាទឲ្យពូកែ
កុំលេងស៊ីផឹកដើរប៉ោខ្វៀ ជាតិខ្មែរចូរចាំបណ្តាំអើយ! ។

ចប់

រោងពុម្ពខ្មែរ

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ

**មូលនិធិខ្មែរសម្រាប់ការសិក្សា** និង **ករុណាខ្មែរ**

ស្កេន ជា eBook ដោយ **គីម វាសនា**

**មេសា ឆ្នាំ ២០១៥**

យើងខ្ញុំសូមថ្លែងអំណរអរគុណ យ៉ាងជ្រាលជ្រៅដល់

**បណ្ឌិតប៉ែន សេដ្ឋារិន**

ដែលបានផ្ញើសៀវភៅនេះមកយើងខ្ញុំ

សម្រាប់ក្នុងការថែរក្សាទុកនិង ផ្សព្វផ្សាយជាទូទៅ

**ដើម្បីបម្រើប្រយោជន៍សាធារណៈ ដោយមិនគិតយកកម្រៃ**

សូមអរគុណ

ខ្លៅ យុនសំរ៉ង

ប្រធាន

មូលនិធិខ្មែរសម្រាប់ការសិក្សា

www.elibraryofcambodia.org